# សម្ដេចសឺន_សាន
# អម្ចាស់ត្រួតត្រាពិភពគុន !!

## Les Seigneur du Monde Obscur

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១៣ មេសា ២០០៦

**មេធ្មប់អារក្សសាតាំង** ៖

លោកសឺន-សានបានចូលមកក្នុងស្រុកខ្មែរដោយលបៗ ហើយនៅពេលគាត់វិលត្រឡប់ទៅវិញ ក៏ដោយលបៗដូចគ្នាដែរ (ដូចចោរ) ។ នៅមុនពេលគាត់ថយខ្លួនទៅសំរាកនៅប្រទេសបារាំង នៅក្នុងឆ្នាំ១៩៦៨ លោកបានសរសេរលិខិតមួយច្បាប់ទៅសម្ដេចសីហនុ មានសេចក្ដីដូច្នេះថា ៖ «ព្រះរាជបំរើរបស់ព្រះអង្គ សូមលាថយទៅចូលនិវត្តន៍ ដោយដើរចំអើតជើង (លបៗ)» («Votre serviteur voudrait rentrer à sa retraite sur la pointe des pieds») ។ កាលនោះ លោកសឺន-សាននៅមានវ័យក្មេងនៅឡើយ (៥៧ឆ្នាំ), គាត់មិនបានចង់ថយទៅសំរាកនោះទេ... ប៉ុន្តែគាត់លាថយដើម្បីទៅធ្វើស្តេចពិភពគុន ។

ដូច្នេះ នៅពេលដែលយៀកកុងនិងយួនខាងជើងវាយប្រហារសំរុកចូលប្រទេសកម្ពុជា តាំងពីខាងកើតរហូតទៅដល់ខាងលិច នៅខែមេសា១៩៧០, លោកសឺន-សានដែលអ្នកផងបានចាត់ទុកថា ជាអ្នកស្នេហាជាតិខ្មែរមួយរូបដែរ បានគេចខ្លួនបាត់ពីដែនដីខ្មែរ (គាត់លេចមុខចេញមក ដើរតួរជាអ្នកស្នេហាជាតិឡើងវិញនៅក្នុងទឹកដីសៀម នៅក្នុងទសវត្ស១៩៨០ ដោយកាន់តំណែងជារដ្ឋមន្ត្រីទី១របស់ប៉ុល-ពតម៉្លោះហើយគ្មានអ្វីគួរឲ្យលំបាកយល់សោះ ដែលថាលោកសឺន-សានជា «មនុស្សក្បាលយួនខ្លួនខ្មែរ»... ហើយនៅពីក្រោយគូថសឺន-សាន ពួកសាធារណរដ្ឋមួយផង់ ដែលរើទៅសហការជាមួយស្តេច មានសក់-ស៊ុតសាខន, ប៉ុក-ថន, អ៊ិន-តាំ, លូ-ឡាយស្រេង សុទ្ធសឹងជាពួក«ក្បាលយួនខ្លួនខ្មែរ»... ពួកអ្នកទាំងនេះ ត្រូវធ្លាក់ចូលក្នុងអន្ទាក់របស់ខ្មែរក្រហមទាំងអស់) ។

នៅក្នុងពិភពភ្លឺ, លោកសឺន-សានគ្រាន់តែមានលក្ខណ:ជារដ្ឋមន្ត្រីទី១ខ្មែរប៉ុណ្ណោះ ប៉ុន្តែនៅក្នុងពិភពងងឹត លោកសឺន-សានជាស្តេចអារក្សសាតាំង ដែលត្រួតត្រាលើផែនដីនេះទាំងមូល ។ នៅគ្រប់ប្រទេសដែលជាបរបក្ខក្នុងវិវាទអាមេរិកាំង-វៀតណាម សម្តេចសឺន-សានមានខ្សែរយ:សាខាទាំងខាងស្តាំនិងទាំងខាងឆ្វេងសំ

រាប់បំរើមហិច្ឆិតារបស់គាត់ទាំងអស់, គឺមហិច្ឆិតារបស់យួនលេបទឹកដីខ្មែរ ឲ្យបានមុនឆ្នាំ២០០០ ៖ នៅសហរដ្ឋអាមេរិក គាត់មានសេអ៊ីអា (គឺស៊្រីងគ្វើរ), នៅបារាំងគាត់មានពួកកុម្មុយនិស្ត, នៅសហភាពសូវៀត គាត់មានកាសេបេ, នៅវៀតណាមគាត់មានផាំ-យ៉ាំងដុង និងឡែ-ឌឹកថ... ហើយនិងង្វៀង-យ៉ាំងធីវ, នៅឡាវ គាត់មានស្តេចសុផានុវង្សនិងខង-ឡែ, នៅប៉េកាំង គាត់មានស្តេចសីហនុ, អ្នកម្នាងម៉ូនិក, ប៉ែន-នុត, ជួន-មុម, ជួន-ប្រសិទ្ធិ, នៅកម្ពុជា គាត់មានចេង-ហេង, អ៊ិន-តាំ, ទ្រិញ-វ៉ាញ, យែម-សំបូរ, ឈាន-វ៉ម, សុស្តែន-ហ្វែរណង់ដេស ។ល។ និង ។ល។ (...ប៉ុន្តែក្នុងពេលសព្វថ្ងៃនេះ គេត្រូវតែធ្វើបង្សុកូលឲ្យខ្មោចសឺន-សាន និងមហិច្ឆិតាយល់សប្តិយល់សូងរបស់គាត់ Requiem of a dream... ពីព្រោះតាំងពីឆ្នាំ២០០០មក ប្រទេសកម្ពុជាដែលបានរលាយទៅជាផេះទៅហើយ ក៏ស្រាប់តែមានកំណើតរស់ឡើងវិញ)

❑

❑ ❑

**<u>បរាជ័យរបស់កម្លាំងទី៣</u>** ៖

នៅក្នុងសៀវភៅរបស់លោក William Shawcross ៖ «The Quality of Mercy - Feeding the Khmer Rouge- p.338 - 339» បានសរសេរដូច្នេះថា ៖

«សឺន-សានធ្លាប់បានធ្វើជារដ្ឋមន្ត្រីនៅក្នុងរដ្ឋាភិបាលសីហនុចំនួន១៧ដង, ប៉ុន្តែបន្ទាប់ពីបានឈ្លោះជាមួយស្តេច គាត់បានទៅរស់ដោយនិរទេសខ្លួន នៅទីក្រុងប៉ារីស នៅចុងទសវត្ស៦០ ។ នៅក្នុងសម័យលន់-នល់ គាត់បានឆ្លៀតទៅធ្វើអន្តរាគមន៍ម្តងម្កាល ដើម្បីបញ្ចប់ការបំផ្លិចបំផ្លាញនៃប្រទេសកម្ពុជា ។ នៅក្នុងខែមករា ១៩៧៤ គាត់បានវិលត្រឡប់ទៅភ្នំពេញ ដើម្បីទៅសុំឲ្យលន់-នល់ ជនខ្វះសមត្ថភាពចាកចេញពីអំណាច (<u>កកន</u> ៖ យើងគួរសម្លឹងមើលឲ្យច្បាស់... គឺលោកសឺន-សាននេះហើយ ជាអ្នកសម្លាប់សាធារណរដ្ឋ ដើម្បីទៅយកស្តេចសីហនុមកជំនួសលន់-នល់, ដូច្នេះបន្ទាប់ពីបានឈ្លោះជាមួយសីហនុ រហូតដល់និរទេសខ្លួន... គាត់បែរជាត្រឡប់ទៅហៅស្តេចសីហនុមកវិញ) ។ មានអ្នកខ្លះបានយល់ឃើញអំពីសឺន-សាន ហើយសឺន-សានខ្លួនឯង ក៏បានយល់ឃើញដូច្នោះដែរ ថាខ្លួនគាត់ជាតំណាងនៃកងកម្លាំងបក្សទី៣នៅប្រទេសកម្ពុជា ។ ដំណោះស្រាយនៃកម្លាំងទី៣នេះ ដែលមិនចូលខាងកុម្មុយនិស្ត ឬក៏មិនចូលខាងស្តាំនិយម ឬអាណានិគមនិយម គឺជាការយល់សប្តិយល់សូងរវើរវាយនៃប្រទេសខាងលិច ដែលបានបង្កើតគំនិតនេះឡើងតាំងពីទសវត្ស១៩៤០ ។ គំនិតនៃកម្លាំងទី៣នេះ បានត្រូវទទួលការចំអកពេបជ្រាយដោយអ្នកនិពន្ធ Graham Greene នៅក្នុងសៀវភៅរបស់គាត់ The Quiet American...» ។

★★★ ដូច្នេះកម្លាំងទី៣នេះ ជាគំនិតរបស់លោកសឺន-សានទេតើ គឺជាមនោគមវិជ្ជាដែលផុសឡើងចេញពីសហការអាមេរិកាំង-យួន ពោលគឺកើតឡើងពីការរួមរ័ក្សរវាងសេអ៊ីអានិងយួនកុម្មុយនិស្ត !! សុវណ្ណាភូម៉ា និងឧត្តមសេនិយខង-ឡែ

នៅឡាវ, ព្រះសង្ឃដុតខ្លួន, ការងើបឡើងរបស់ឧត្តមសេនិយដួង-យ៉ាំងមិញ, ការពីឃាតប្រធានាធិបតីង៉ោ-ឌិនយៀមនៅវៀតណាមខាងត្បូង, ការជំរុញឲ្យឧត្តមសេនិយដាប-ឈួនក្បត់ស្តេចនៅប្រទេសកម្ពុជា... ការដាក់គ្រាប់បែកបំផ្ទុះវាំងខ្មែរ... ការបង្កើតបុគ្គលិកលក្ខណៈ ឬស្សួនគួរបស់ស្តេចសីហនុជាអ្នកមានបុណ្យ, ការបំផុសព្រឹត្តិការណ៍១៨មីនា១៩៧០ ក្នុងប្រការបង្កើតសាធារណរដ្ឋខ្មែរ, និងការជំរុញទៅរកព្រឹត្តិការណ៍១៧មេសា១៩៧៥ ដើម្បីយកស្តេចសីហនុមកជំនួសលោកលន់-នល់វិញ ក្នុងគោលប្រាថ្នាទប់ទល់ជាមួយនឹងពួកក្រហម... គឺសុទ្ធសឹងជាលទ្ធផលមនោគមវិជ្ជាកម្លាំងទី៣ (របស់សឺន-សាន) ដែលជាអន្តរាគមន៍រួមគ្នារវាងអាមេរិកាំង-វៀតណាមទាំងអស់ ។

នៅចន្លោះឆ្នាំ១៩៧០និង១៩៧៥ ខ្លួនខ្ញុំផ្ទាល់បានឃើញលោកសឺន-សានធ្វើដំណើរលបៗទៅប្រទេសកម្ពុជា ដើម្បីទៅជួបលោកចេង-ហេងប្រមុខរដ្ឋ ។ កាលនោះខ្ញុំមានគំនិតពេបជ្រាយទៅលើលោកសឺន-សាន ដោយនឹកស្មានថា គាត់ទៅសុំបុណ្យសាធារណរដ្ឋ តាមពិតគាត់ទៅបំបះបំបោរផ្តួលព្រលុំរបបលន់-នល់ទៅវិញសោះ ។ លោកចេង-ហេងនេះ ជាកូនធម៌របស់លោកប៉ែន-នុត... ហើយមកដល់ឡូងប៊ីចទៅហើយ គាត់បានប្រាប់ខ្ញុំថា គាត់គោរពលោកប៉ែន-នុតណាស់ ។ ពេលលោកសឺន-សានបានជួបលោកចេង-ហេងរួចហើយ តាមរយៈខ្មែរ-យួនម្នាក់ឈ្មោះ នាង-ជិនហាន ដែលជាអតីតភូឈ្មួយទី១នៅខេត្តព្រៃវែង (សម័យលោកសៅ-ឌៀប), លោកចេង-ហេងក៏រំដោះប្អូនស្រីម្នាក់ ជើងឯកខាងវាយពីងប៉ុង ទៅបំរើសម្តេចសីហនុនៅប៉េកាំង (សូមអានអារម្ភកថារបស់លោក Wilfred Burchett នៅក្នុងសៀវភៅ My War with the CIA) ។ ក្នុងពេលជាមួយគ្នានោះ លោកសឺន-សានក៏បានរំដោះក្មួយរបស់អ្នកម្នាងម៉ូនិកម្នាក់ឈ្មោះ ស៊ីសុវត្ថិ-ថូមីកូ ពីទីក្រុងប៉េកាំងឲ្យមកបំរើទ្រង់ស៊ីសុវត្ថិ-សិរិមតៈនៅទីក្រុងភ្នំពេញវិញ ។

នៅក្នុងដំណើរចុងក្រោយរបស់លោកសឺន-សានទៅកាន់សាធារណរដ្ឋខ្មែរនៅខែមករា១៩៧៤, លោកសឺន-សានក៏ស្រាប់តែអំពាវនាវនៅក្នុងសន្និសិទសារពត៌មានមួយ នៅមហាវិទ្យាល័យច្បាប់ ឲ្យលោកលន់-នល់ថយចេញពីអំណាចតែម្តង។ គឺនៅចំពេលដែលសាធារណរដ្ឋខ្មែរ ដែលរស់ផ្តេតៗដោយសារតែអង្ករអាមេរិកាំងដឹកមករាប់រយកប៉ាល់តាមទន្លេមេគង្គ រង់ចាំផ្តល់តែដង្ហើមចុងក្រោយប៉ុណ្ណោះ ។

លោក ស្រី-ធីរ៉ា ក្មួយបង្កើតរបស់ទ្រង់សិរិមតៈបាននិយាយប្រាប់ខ្ញុំថា នៅពេលនោះ លោកសឺន-សានបានទៅកំហែងទ្រង់សិរិមតៈឲ្យសម្លាប់ខ្លួន ។ ទាំងនេះគឺជាសំដីរបស់លោកសឺន-សានផ្ទាល់ ទៅកាន់ទ្រង់សិរិមតៈ ៖

«បើទ្រង់សម្លាប់ខ្លួនទៅ ដើម្បីលាងកំហុសថ្វាយសម្តេចសីហនុ នោះគឺមានតែទ្រង់ម្នាក់ទេដែលត្រូវលះបង់, ក៏ប៉ុន្តែគឺប្រជារាស្ត្រខ្មែរមួយនគរ តែត្រូវរួចរស់ជីវិត» ។ យោងតាមសៀវភៅបារាំងមួយឈ្មោះ Le Portail, Edition de la Table Ronde,

ទ្រង់សិរិមត:, ដែលត្រូវលាក់ខ្លួនយ៉ាងស្ងាត់និងយ៉ាងជិតបំផុតនៅក្នុងស្ថានទូតបារាំង ចំនួន៣អាទិត្យរួចមកហើយ បន្ទាប់ពីថ្ងៃ១៧មេសា១៩៧៥ ក៏ត្រូវពួកភ្នាក់ងារខ្មែរក្រហម ឬយួន (ឬក៏ភ្នាក់ងាររបស់លោកសឺន-សាន) មកកំហែងនាំខ្លួនទៅបាត់ ដោយចោទទ្រង់ (មិនចំឈ្មោះ) ថាជា«មេក្រុមសេអ៊ីអាជាន់ខ្ពស់» ។ ការមកទាមទារនាំខ្លួនទ្រង់សិរិមត:បានធ្វើឡើងច្រើនដងច្រើនសា ។ ពួកបារាំងងឿងឆ្ងល់ណាស់ ហេតុអ្វីបានជាពួកខ្មែរក្រហមដឹងថាទ្រង់សិរិមត:លាក់ខ្លួននៅក្នុងឋានទូត (ប្រហែលជាដឹងមកពីភ្នាក់ងារចិនឬវៀតណាម?) ក៏ប៉ុន្តែទោះជាពួកបារាំងខំប្រឹងប្រកែកយ៉ាងណាក៏ដោយថា «គ្មានភ្នាក់ងារជាន់ខ្ពស់របស់សេអ៊ីអា» នៅក្នុងឋានទូតបារាំងទេ ក៏លោកភារធារីបារាំងមានកាតព្វកិច្ចត្រូវតែនាំខ្លួនទ្រង់សិរិមត:ទាំងទើសទាល់ មកប្រគល់ឲ្យពួកខ្មែរក្រហម ។ ពេលនោះទ្រង់សិរិមត:ពាក់ខោអាវធំ (Tenue de Ville) ពាក់វ៉ែនតាខ្មៅ កាន់ Suitcase មួយ ដើរចេញមកពីបន្ទប់ងងឹត ដោយគ្មាននិយាយស្តីអ្វីមួយម៉ាត់ មកប្រគល់ខ្លួនឲ្យពួកខ្មែរក្រហម ដែលនៅឈរចាំទ្រង់នៅខាងក្រៅបន្ទប់ជាស្រេច ។

ដូច្នេះគេមើលឃើញថា មហាអំណាចបារាំងបាន «លក់ខ្លួន» ទ្រង់សិរិមត:ទៅឲ្យខ្មែរក្រហមពិឃាត ដូចតែមហាអំណាចរ៉ូម៉ាំង បានប្រគល់ខ្លួនព្រះយេស៊ូ ឲ្យជនជាតិជ្វីហ្វយកទៅឆ្កាង (ដូចតាមសំណើររបស់សម្តេចសឺន-សាន ក្នុងឆ្នាំ១៩៧៤ នោះដែរ) ។ ប៉ុន្តែទ្រង់សិរិមត:ក៏មិនបានក្លាយទៅជាអង្គព្រះយេស៊ូ ឬព្រះអង្គសង្គ្រោះឯណាទេ ។ ហើយនៅពេលដែលទ្រង់ត្រូវ«សម្លាប់ខ្លួន»ទៅ (ដោយព្រោះទ្រង់មិនព្រមរត់ចេញមុនព្រឹត្តិការណ៍)... ប្រជារាស្ត្រខ្មែរមួយនគរក៏មិនបានរួចខ្លួន ពីការផ្តន្ទាទោសរបស់សម្តេចសីហនុ ដូចយោបល់មេធ្មប់នៃកម្លាំងទី៣នោះដែរ (សម្តេចសឺន-សាន) ។

❑

❑ ❑

**<u>ភ្នែកមុតរបស់ខៀវ-សំផន</u>** ៖

★★★ ខ្ញុំមានយោបល់ថា បរាជ័យនៃកម្លាំងទី៣នៅកម្ពុជា ពោលបរាជ័យនៃសហការអាមេរិកាំង-យួន តទល់ជាមួយពួកខ្មែរក្រហម គឺបណ្តាលមកពី <u>ភ្នែកមុតរបស់ខៀវ-សំផន ដែលបានក្រឡេកឃើញថា លោកសឺន-សានជាជនជាតិយួន ព្រមទាំងជាភ្នាក់ងារជាន់ខ្ពស់របស់សេអ៊ីអាផងដែរ តាំងពីយូរយារណាស់មកហើយ</u> ។ តាំងពីកាលណាមក ? ខ្ញុំមិនអាចសន្និដ្ឋានបានទេ ក៏ប៉ុន្តែនៅថ្ងៃទី១៧កក្កដា១៩៧៤ លោកខៀវ-សំផនមេបញ្ជាការកងទ័ពខ្មែរក្រហម បានផ្ញើសារទូរលេខសម្ងាត់ជាភាសាបារាំង១ច្បាប់ តាមរយ:ជួន-ប្រសិទ្ធ ថ្វាយទៅសម្តេចសីហនុនៅប៉េកាំង ដែលមានសេចក្តី (ដកស្រង់) ដូច្នេះថា ៖

«២- ខ្មាំងសត្រូវកំពុងធ្លាក់ទ្រុឌទ្រោមយ៉ាងខ្លាំង ដោយវិបត្តិជម្លោះផ្ទៃក្នុង ដែ-

លមិនអាចមានដំណោះស្រាយ ។ ពួកក្លង់ផ្សេងៗដែលបានធ្វើរដ្ឋប្រហារ កំពុងតែហែកហួរប្រខាំគ្នាស្លាប់រស់ ដើម្បីដណ្តើមចែកអំណាច ។ នៅក្នុងពេលបច្ចុប្បន្ននេះ ខ្មាំងសត្រូវកំពុងហែលឆ្លងវិបត្តិធ្ងន់ធ្ងរ ដែលផ្ទុះឡើងទាំងកណ្តាលថ្ងៃត្រង់ ដែលគ្រប់មជ្ឈដ្ឋាននៅភ្នំពេញ អាចមើលឃើញនិងដឹងឮ ។ លន់-នល់ហើយនិងបនកំពុងភ័យគ្រប់ពេលវេលា ខ្លាចក្រែងមានរដ្ឋប្រហារមួយទៀត សំដៅទៅលើពួកវា ។ ចំណែកពួករដ្ឋាភិបាលក្បត់វិញ កំពុងតែស្រុតចុះដោយករណីទំនាស់ផ្ទៃក្នុងផ្សេងៗ ហើតដែលអនាធិបតេយ្យកំពុងតែរាតត្បាតពេញទំហឹង» ។

«ឧទាហរណ៍ ៖ ប៉ាន់-សូធី (កកន ៖ មេកើយរបស់ប៉ុក-ថន ដែលជានិន្នាការកុម្មុយនិស្ត នៅក្នុងក្រុមរបស់ហង្ស-ធុនហាក់) ប៉ាន់-សូធីកំពុងតែមានមហិច្ឆិតាលោភលន់ចង់បានតំណែងរដ្ឋមន្ត្រីទី១អោយបាន ដែលជាកន្លែងសព្វថ្ងៃរបស់ឡុង-បូរ៉េត ។ ក៏ប៉ុន្តែពួកចក្រពត្តិអាមេរិកាំង មិនទាន់អនុញ្ញាតឲ្យជននេះបានដូចចិត្តនៅឡើយទេ ។ ពួកវាចង់ឲ្យឡុង-បូរ៉េតនៅកន្លែងដដែល ក្នុងប្រការបញ្ជូនឡុង-បូរ៉េតទៅអង្គការសហប្រជាជាតិ ដើម្បីការពារផលប្រយោជន៍របស់ពួកក្បត់ ។

«៣- បរាជ័យរបស់ក្រុមសឺន-សាន, ចៅ-សៅ - ក្រុមនេះមិនទាន់មានលទ្ធភាពនិងសមត្ថភាព ដើម្បីបង្កើតអ្វីៗដែលគេហៅថា កម្លាំងទី៣ នោះទេ ក្នុងគោលបំណងប្រយុទ្ធជាមួយនឹងក្លង់លន់-នល់ ។ សព្វថ្ងៃនេះក្លង់អ៊ិន-តាំ, សឺង-ង៉ុកថាញ់ដែលនៅបំរើពួកសេអ៊ីអា បានកាន់កាប់ក្រុមនេះរួចទៅហើយ» ។

★★★ ដែលខៀវ-សំផនសំដៅទៅកម្លាំងទី៣កាលសម័យនោះ គឺគណបក្សប្រជាធិបតេយ្យក្បាលដីរ ដែលមានមេដឹកនាំឈ្មោះថា អ៊ិន-តាំ, ឌុក-រ៉ាស៊ី និងចៅ-សៅ ៖ ពួកអ្នកទាំងនេះសុទ្ធសឹងតែបានស្រែកអំពាវនាវឲ្យសម្តេចសីហនុ យាងត្រឡប់មកភ្នំពេញវិញ (តាមសំណើរសឺន-សាន) ។ ការដែលគួរឲ្យកត់សម្គាល់ ៖

ទី១- អ៊ិន-តាំនិងឌុក-រ៉ាស៊ី សុទ្ធសឹងតែជាអ្នកបានទម្លាក់ស្តេចសីហនុ កាលក្នុងព្រឹត្តិការណ៍១៨មីនា១៩៧០ ។ ចុះម្តេចបានជានៅក្នុងឆ្នាំ១៩៧២ ពួកដដែលនេះបែរជាហៅស្តេចសីហនុឲ្យត្រឡប់វិលវិញ ?? ដូច្នេះនៅពេលនោះ ខៀវ-សំផនដឹងច្បាស់ណាស់រួចទៅហើយថា ពួកកម្លាំងទី៣ មានសឺន-សាន, ចៅ-សៅ, អ៊ិន-តាំ និង ឌុក-រ៉ាស៊ី សុទ្ធសឹងតែជាពួក «ក្បាលឃួនខ្លួនខ្មែរ» ។ ការទម្លាក់ស្តេចសីហនុ ជាការបង្កើតឲ្យមានសង្គ្រាម រវាងពួកសាធារណរដ្ឋនិងពួកស្តេចរួចទៅហើយ ក៏ប៉ុន្តែការទាមទារយកស្តេចមកវិញ គឺជាគំរោងរបស់ឃួនបង្កើតសង្គ្រាមមួយបន្តទៀតរវាងសីហនុហើយនិងខៀវ-សំផន !!

ទី២- លោកឌុក-រ៉ាស៊ី ជាបញ្ញាជនស្តាំនិយម, លោកជាបក្សពួកសឺង-ង៉ុកថាញ់ពិតមែន ពីព្រោះខ្ញុំបានជួបលោកប៉ាជ-ឈឺន ហើយនិងលោកតាសឺង-ង៉ុកថាញ់នៅផ្ទះលោកឌុក-រ៉ាស៊ី នៅកណ្តាលឆ្នាំ១៩៧០ (លោកប៉ាជ-ឈឺន ដែលចាស់ជរាណាស់ទៅហើយបាននិយាយមកកាន់ខ្ញុំថា ៖ «ខ្ញុំអរណាស់ ដែលបានឃើញស្តេចសីហ

នុជ្ជលរលំ នៅមុនពេលខ្ញុំស្លាប់... តែប៉ុណ្ណោះខ្ញុំបិទភ្នែកជិតហើយ» ។ ចំណែកលោកសឹង-ង៉ុកថាញ់វិញបាននិយាយមកកាន់ខ្ញុំ ដោយយកដៃកៀកស្មា ៖ «ខ្ញុំប្រឹងជួយផងកនយើង...ខ្ញុំប្រឹងជួយស្តារប្រទេសជាតិយើងឡើងវិញ!» ។

ក៏ប៉ុន្តែចៅហ្វាយរបស់លោកឌុក-រ៉ាស៊ី មិនមែនលោកតាសឹង-ង៉ុកថាញ់ទេ... ចៅហ្វាយរបស់លោកឌុក-រ៉ាស៊ី គឺលោកសឺន-សាន, គ្រូឧបជ្ឈាយ៍នៃកម្លាំងទី៣ ។ លោកឌុក-រ៉ាស៊ីជាជនស្តាំនិយម ជាបក្សពួកសេអ៊ីអា ម្តេចបានទៅចូលរួបរួមជាមួយចៅ-សៅ (ជនកុម្មុយនិស្តដែលមាននិន្នាការហាណូយ?) ។

★★★ ទៅថ្ងៃមុខទៅ ខ្ញុំបានឃើញផ្ទាល់ភ្នែក នៅទីក្រុងឡុងប៊ីច ថាលោកឌុក-រ៉ាស៊ី ជនស្តាំនិយមនិងជាអ្នកបំរើសេអ៊ីអា បានទៅស្នាក់នៅផ្ទះលោកប៉ុក-ថន ជនកុម្មុយនិស្តដែលបំរើសេអ៊ីអាដូចគ្នា ហើយគាត់ទាំងពីរនេះជាកូនចៅរបស់មេធ្មប់សឺន-សានទាំងអស់គ្នា ។

ដូច្នេះ ខ្ញុំគួរអនុម័តថា ខៀវ-សំផនបានស្គាល់តាំងពីទសវត្ស៧០មកម្ល៉េះនូវស្ទួនតួបុគ្គលិកលក្ខណៈពីររបស់លោកសឺន-សាន គឺជាឧបជ្ឈាយ៍ខាងយួនកុម្មុយនិស្តផង... គឺជាឧបជ្ឈាយ៍ខាងសេអ៊ីអាផង ។ ម្ល៉េះហើយយើងត្រូវស្គាល់ភាសារបស់ខៀវ-សំផន ៖ កាលណាខ្មែរក្រហមជេរថា ៖ «សេអ៊ីអា» គឺពួកវាសំដៅទៅលើយួន... កាលណាពួកខ្មែរក្រហមជេរថា «អាយួន» គឺពួកវាសំដៅទៅលើ«សេអ៊ីអា»... គឺទៅលើសឺន-សាន !!

★★★ ចំណែកភ្នែកខ្មែរយើងនៅឡុងប៊ីចវិញ ត្រូវមើលបញ្ច្រាស់ ដើម្បីយល់ពីប្រស្នារបស់ខៀវ-សំផន... កាលណាភាសាខាងយើងចោទថា «អាខ្មែរក្រហម» នោះត្រូវសំដៅទៅលើពួកសេអ៊ីអា, កាលណាយើងចោទថា «សេអ៊ីអា» នោះគឺជាពួកអាខ្មែរក្រហម... គឺសំដៅទៅលើសឺន-សានដូចគ្នា !!!

ទី៣- ឧត្តមសេនីយ៍សក់-ស៊ុតសាខន គឺជាជំរើសរបស់សឺន-សាន ដើម្បីជំនួសលោកលន់-នល់ (Acting Chief of State) នៅដើមខែមេសា៧៥ ។ ដូច្នេះនៅពេលដែលលោកសឺន-សានហើយនិងលោកសក់-ស៊ុតសាខនទៅបង្កើតការតស៊ូនៅព្រំប្រទល់ដែនថៃ ដោយទៅរួបរួមជាមួយពួកខ្មែរក្រហម គឺខៀវ-សំផនដឹងច្បាស់ណាស់ថា អ្នកទាំងពីរមិនមែនមកបំរើផលប្រយោជន៍ខ្មែរទេ តែមកបំរើផលប្រយោជន៍យួន ។ ជម្លោះរវាងសឺន-សាននិងសក់-ស៊ុតសាខន គឺជាទង្វើក្លែងក្លាយ ដើម្បីលាក់បំបាំងគំរោងការពិតប្រាកដ ៖ គឺការរំលាយកងទ័ពខ្មែរសេរី ដើម្បីកុំឲ្យមានកម្លាំងទប់ទល់ជាមួយនិងយួន... (ប្រសិនបើយើងជាខ្មែរក្រហមវិញ ត្រូវធ្វើយ៉ាងណា ? គឺច្បាស់ជាទុកឲ្យពួកសឺន-សាន ហើយនិងពួកសក់-ស៊ុតសាខនសម្លាប់ខ្លួនឯងតែប៉ុណ្ណោះ !) ។

## នៅឡុងប៊ីច គេបានបង្កើតជម្លោះក្លែងក្លាយ

ទី១- ជម្លោះអ៊ិន-តាំ / សឺន-សាន ៖

គេបានបង្កើតក្រុមស្អប់ខ្មែរ«១៧មេសា» មានអ៊ិន-តាំ, ជាវ-ឡាវ, យ៉ង-សែម, តុល-លាស់, ហើយគេបានបង្កើតក្រុមគាំទ្រ «១៧មេសា» មាន សឺន-សាន, ប៉ុក-ថន, ហ៊ុយ-កន្ធុយរ៉ា...។ គេបានបង្កើតឲ្យមានជម្លោះរវាងខ្មែរនិងខ្មែរ និងឲ្យមានការភ័ន្តរង្វេងក្នុងមតិមហាជន ។ តាមពិតក្រុមទាំងពីរនេះ ជាក្រុមតែមួយ ហើយបានរត់ទៅបំរើយួនទាំងអស់គ្នា ។

ទី២- ជម្លោះសឺន-សាន / សក់-ស៊ុតសាខន ៖

ជម្លោះនេះមិនដឹងជាមានបុព្វហេតុអ្វីពិតប្រាកដទេ ស្រាប់តែថ្ងៃមួយ លោកថាច់-សួន ដែលជាជំនិតលោកប៉ុក-ថន បានមកបបួលខ្ញុំឲ្យ «កាប់ក្បាលសឺន-សាន» ។ មានទាំងសេអ៊ីអាមែនទែន លោក Dennis Cameron ជនម្នាក់ស្លូតបូតហើយទន់ភ្លន់ បានមកស្នើរដល់រូបខ្ញុំ ឲ្យបញ្ចេញយោបល់ក្នុងករណី «បាញ់សម្លាប់លោកសឺន-សាន... ពីព្រោះជាមនុស្សចាស់គំរិលពុករលួយដើរថយក្រោយ... ដែលធ្វើឲ្យខូចកិច្ចការពួកខ្មែរសេរីនៅព្រំប្រទល់» ។ ចំណែកលោកដៀង-ដែលឯណោះបានសរសេរលិខិតមួយច្បាប់ជាភាសាបារាំង ទៅចុះផ្សាយក្នុងព្រឹត្តិប័ត្រ«មូលខ្មែរ» ដោយចោទថា លោកសឺន-សានបានទទួល៥០ម៉ឺនដុល្លារពីប្រទេសចិន តែពុំបានយកប្រាក់នេះទៅប្រគល់ឲ្យរ.ជ.រ.ប.ខ.នោះទេ គឺគាត់យកទៅដាក់ហោប៉ៅខ្លួនឯងវិញ ។ តាមពិតសឺន-សាន, អ៊ិន-តាំ, សក់-ស៊ុតសាខន ជាក្រុមកម្លាំងទី៣ ដែលបានផ្តួលព្រលំរបបសាធារណរដ្ឋរបស់លោកលន់-នល់ ហើយជំរុញឲ្យមានព្រឹត្តិការណ៍១៧មេសា១៩៧៥ ។ គឺជាពួកក្រុមជនតែមួយឆ្លេឆ្លា, ចាក់ខ្សែ គ្មានជំនឿលើអ្វីពិតប្រាកដជាពួកត្រីងៀតឆ្អៀតពង មានឧត្តមគតិឃ្លេងឃ្លោង ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយ ៖ គឺជាពួកជនសេរីដែលទៅសហការជាមួយកុម្មុយនិស្ត (សឺន-សាន) ។ គឺជាពួកកុម្មុយនិស្តដែលមាន «សួនតូ រ៉ូម៉ង់ទិក» ជាសេរី ហើយដើរថែចង់ស្រីរបៀប Jean-Jacques Rousseau និង Maupassant (ប៉ក-ថន) ។ គឺជាពួកសាធារណរដ្ឋដែលរត់ចូលស្តេច (សក់-ស៊ុតសាខន, តុល-លាស់, លូ-ឡាយស្រេង, ឃី-តាំងលឹម) ។ គឺជាពួកស្តេចដែលរត់ចូលយួន (យ៉ង-សែម, អ៊ិន-តាំ, ចេង-ហេង) ។ គឺពួករត់ចូលប៉ុល-ពត ដើម្បីទៅថ្កោលទោសហ៊ុន-សែន ។ ហើយបន្ទាប់មកក៏រត់ទៅចូលហ៊ុន-សែន ដើម្បីថ្កោលទោសប៉ុល-ពត (គឺទាំងអស់គ្នាខាងលើ) ។ ក្នុងករណីនេះ តើសឺន-សាន ដែលមានអាមេរិកនិងអន្តរជាតិនៅពីក្រោយខ្នង អាចកាត់ទោសប៉ុល-ពតម្តេចនឹងបាន បើខ្លួនគាត់មានឋានៈជារដ្ឋមន្ត្រីទី១របស់ប៉ុល-ពតនៅព្រំប្រទល់, ហើយបន្ទាប់មកទៀត តើសឺន-សានមានលទ្ធភាពឯណាទៅកាត់ទោសហ៊ុន-សែន បើគាត់ជាជនជាតិយួន ។ ឃើញថា ពួកកម្លាំងទី៣របស់សឺន-សាននេះ មានច្រកចេញតែមួយ ៖ ធុងសម្រាមនៃប្រវត្តិសាស្ត្រ (La Poubelle de l'Histoire) ។ បើពួកគេរត់ចូលព្រៃ គេនឹងប្រទះប៉ុល-ពត, បើពួកគេរត់ចូលក្រុង ពួកគេនឹងប្រទះហ៊ុន-សែន !! សំរេចសំរួចទៅ ពួកសឺន-សានដែលមានអ្នកចេះដឹងមួ

យផែនដីនៅពីក្រោយខ្នង មានសម-រង្ស៊ី, អ្នកស្រីក្អិក-កាឡាប្រ៊ូ, ជា-វណ្ណាត, លោកដុកទ័រឡៅ-ម៉ុងហៃ, ស៊ាន-ប៉េងសែ, សាយ-បូរី, Peter Leprech (អ.ស.ប.) ឋានទូតស.រ.អា., ពួកសេអ៊ីអា ឬពួកអាមេរិកាំងស្តាំនិយមនានានៅវ៉ាស៊ិនតោន... ក៏នៅតែធ្វើកូនឈ្លបតូចមួយរបស់ប៉ុល-ពត (ហ៊ុន-សែននោះ) មិនបែកផង... កុំថាឡើយដល់ទៅប្រឡងជាមួយខៀវ-សំផន ! ឥឡូវនេះហ៊ុន-សែនដើរផ្សាយគ្រប់ទីកន្លែង ៖ «ប្រយ័ត្នអញប្រើអាមេរិកាំង ឲ្យចាប់ខ្លួនដូចអាយ៉ាសិទ្ធ...» ។

❑

❑ ❑

## សហការអាមេរិកាំង-យួន ដើម្បីប្រល័យពូជសាសន៍ខ្មែរ

នៅក្នុងសៀវភៅ The Quality of Mercy - p.354 មានសរសេរថា ៖ «នៅឆ្នាំ១៩៨២ សីហនុហើយនិងសីន-សាន នៅទីបញ្ចប់ក៏បានត្រូវណែនាំ (កកន ៖ ដោយប្រទេសខាងលិច) ឲ្យធ្វើសហការជាមួយគ្នា ព្រមទាំងឲ្យបង្កើតរដ្ឋាភិបាលចំរុះជាមួយនឹងសត្រូវរួមរបស់ពួកគេ គឺពួកខ្មែរក្រហម ។ រដ្ឋាភិបាលថ្មីមួយ ដែលមានដាក់សីហនុជាក្បាលម្តងទៀត ក៏ត្រូវបានប្រកាសឡើង ។ នេះជាការបន្តប្រវត្តិសាស្ត្រដែលដ៏គួរឲ្យតក់ស្លុត ។ សីហនុបានត្រូវដាក់ជាផ្លូវការ ឲ្យធ្វើមេដឹកនាំរណសិរ្សរួបរួម ដែលមានពួកខ្មែរក្រហមលាយចំរុះម្តងរួចទៅហើយ នៅក្នុងសង្គ្រាម១៩៧០-១៩៧៥ ហើយដូចស្តេចសីហនុបានថ្លែងនៅក្នុងឆ្នាំ១៩៧៣ដូច្នោះឯង ពួកនេះបាន«ខ្ទាក់ទ្រង់ចោលដូចគ្រាប់ផ្លែ Cherry» បន្ទាប់ពីពួកគេបានទទួលជោគជ័យកាលណាហើយបន្ទាប់ពីពួកគេលែងត្រូវការទ្រង់ (កកន ៖ ហ៊ុន-សែនសព្វថ្ងៃ ក៏មានបុកពារកោងកាច ក៏ដូចតែអៀង-សារីកាលសម័យមុន, គឺបានខ្ទាក់ស្តេចសីហនុចោលដូចគ្រាប់ផ្លែ Cherry) ។ បើទោះជាមានបទពិសោធន៍យ៉ាងដូចនេះក៏ដោយ ឈ្មោះទ្រង់ក៏បានត្រូវអនុញ្ញាតសាជាថ្មី យកទៅប្រើជាប្រមុខរដ្ឋទីងមោងរបស់ពួកខ្មែរក្រហម។ ចំពោះសីន-សានក៏ដូច្នោះដែរ គឺជាការចប់នៃសេចក្តីសង្ឃឹមថា បានជាតំណាងកម្លាំងទីពបុទី៤ ។ នៅក្នុងឆ្នាំ១៩៨២ អង្គប្រជុំវិសាមញ្ញនៃអង្គការសហប្រជាជាតិបានបោះឆ្នោតដោយសម្លេងច្រើនលើសលប់ជាងពីមុនទៅទៀត ដើម្បីរក្សាទុករបបកម្ពុជាប្រជាធិបតេយ្យ ហើយបដិសេធរបបហេង-សំរិន ។ ព្រឹត្តិការណ៍ដដែលនេះបានកើតឡើងសាជាថ្មីម្តងទៀតនៅឆ្នាំ១៩៨៣...» (កកន ៖ គួរកត់សម្គាល់ថា សៀវភៅលោក Shawcross បានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ១៩៨៤) ។

★★★ ដូច្នេះ តាំងពីឆ្នាំ១៩៧៩, សហការអាមេរិកាំង-សីនសាន បានប្រោសលោះឲ្យរបបប៉ុល-ពតរស់ឡើងវិញ ។ កាលពីដប់ឆ្នាំមុននេះ (១៩៦៩) សហការសីនសាន-គីស្ស៊ីងគ្ញើរទម្លាក់គ្រាប់បែកនៅប្រទេសកម្ពុជា បានបង្កើតឲ្យមានរបបប្រល័យពូជសាសន៍ពិឃាដវង្កាល នៅថ្ងៃទី១៧មេសា១៩៧៥, តែនៅចាប់ផ្តើមទសវត្ស ៨០ សហការអាមេរិកាំង-សីនសានដដែល ដោយមានពួកថៃជាដៃជើង បានរុញ

ច្រានប្រជាជនខ្មែរភៀសខ្លួនទាំងហ្វូងទាំងហ្វាយទៅឲ្យពួកខ្មែរក្រហមសម្លាប់ម្ដងទៀត ។ លោក John Gunther Dean, កូនចៅរបស់ Kissinger អគ្គរដ្ឋទូត ដែលបានឱបទង់ជាតិអាមេរិកាំង រត់«ប្រាស់អាយ៉ូស»នៅចំពោះមុខពួកខ្មែរក្រហម ដោយទម្លាក់សាធារណរដ្ឋខ្មែរ ឲ្យធ្លាក់ជាចំណីនៃទីលានពិឃាត នៅថ្ងៃទី១១មេសា១៩៧៥ នៅពេលដែលគាត់បានទៅតំណាងប្រយោជន៍អាមេរិកាំងនៅបាងកក (សម័យរដ្ឋការ Reagan) បានថ្លែងប្រកាសយ៉ាងកាចសាហាវថា ៖ «ខ្ញុំជារដ្ឋទូតតំណាងប្រយោជន៍ប្រជាជនថៃ... មិនមែនជារដ្ឋទូតរបស់ប្រជាជនភៀសខ្លួននោះទេ» ។

ជាពិសេស តាំងពីឆ្នាំ១៩៨០មក ទាហាន«សេរីនិយមព្រះពុទ្ធសាសនា»របស់សឺន-សាន បានសហការជាមួយឃាតករខ្មែរក្រហមដោយចំហតែម្ដង ។ ប៉ុន្តែសឺនសានពុំមែនជាអ្នកកាន់ព្រះពុទ្ធសាសនានោះទេ, កាលណានៅកំបាំងមុខជនជាតិខ្មែរសឺន-សានកាន់សាសនាព្រះយេស៊ូ ។ ជាពិសេស មេសាសនាកាតូលិកបារាំង (Père Venet), ពួកផ្សាយដំណឹងល្អអាមេរិកាំង, The Seventh Day Adventist, the Christian and Missionnary Alliance មានរហូតដល់ម្ចាស់ក្សត្រី Grace de Monaco សុទ្ធសឹងតែជាពួកខ្ញុំបំរើដាច់ថ្លៃរបស់សឺន-សានទាំងអស់ ។ មិនត្រឹមតែប៉ុណ្ណោះ ដោយមិនគិតពីក្រុមសេអ៊ីអា ដែលមានខ្លួនគាត់ជាភ្នាក់ងារជាន់ខ្ពស់បំផុតរួចទៅហើយ, សឺន-សានមានអង្គការពិភពលោកមួយផង UNHCR, UNBRO, UNICEF, ICRC (កាកបាទក្រហម), World Vision, Oxfam... ដែលចាំតែគាំទ្ររូបគាត់ ដោយគ្រាន់តែកំរើកម្រាមដៃ ។ ដូច្នេះសឺន-សានមានអំណាចជាស្ដេចអធិរាជក្នុងប្រការ ចែកម្ហូបអាហារដល់ប្រជាជនភៀសខ្លួន និងមាន Quota នៅក្នុងដៃ សំរាប់បញ្ជូនអ្នកទាំងនេះទៅប្រទេសទី៣ ។ ក៏ប៉ុន្តែអំណាចដ៏ធំធេងនេះ សឺន-សានបែរជាយកទៅចែកចាយជាមួយពួកថៃ ដើម្បីរុញច្រានប្រជាជនខ្មែរ ទៅឲ្យប៉ុល-ពតសម្លាប់ទៅវិញ ។ កាលនោះពួកខ្មែរក្រហមមិនបានបង្ហាញអំពីការធូរថយនៃអំពើឃោរឃៅរបស់ខ្លួននៅឡើយទេ... ស័ក្តិ៥ខ្មែរក្រហមឈ្មោះ ផាក-លឹម នៅសាកែវ (កាន់ព្រះពុទ្ធសាសនា) បានចាប់ជនភៀសខ្លួនយកមកជាន់លើដែកក្ដៅ (ដុតភ្លើង) ស្រែកទ្រហោរងួយពេញព្រៃ ទាំងកណ្ដាលថ្ងៃត្រង់ នៅចំពោះមុខពួកអង្គការមនុស្សធម៌ និងពួកយោធាថៃរបស់សឺន-សានតែម្ដង ។ ចំណែកកម្មាភិបាល មិត្តថុន នៅណងព្រួ (នាមដើមឈន-ហៃ, លេខាធិការផ្ទាល់របស់ខៀវ-សំផន) បានផ្សាយពាក្យស្លោកដូចនេះ ៖

«ពួកត្រឡប់ទៅវិញទី១ បានដេកគ្រែ
ពួកត្រឡប់ទៅវិញទី២ បានដេកពូក
ពួកត្រឡប់ទៅវិញទី៣ ដេកក្នុងភក់
ពួកត្រឡប់ទៅវិញទី៤ ដេកក្រោមដី» ។

ទោះជាយ៉ាងនេះក្ដី សឺន-សានសហការជាមួយពួកថៃជាអចិន្ត្រៃយ៍ ដើម្បីច្បាម

គ្រវែងប្រជាជនខ្មែរភៀសខ្លួន ឲ្យទៅជាចំណីរបស់ប៉ុល-ពត ៖ គឺបានចាប់បញ្ជូនខ្មែររាប់ពាន់នាក់ ទាំងក្មេងទាំងចាស់ប្រុសស្រី ទៅចាក់ចោលនៅព្រះវិហារ, បានចាប់បញ្ជូនប្រជាជនខ្មែររាប់ម៉ឺននាក់ ពីជំរំខៅអ៊ីដាង មកដាក់ក្នុងជំរំសឺន-សាន, ជំរុញប្រជាជនស៊ីវិលចំនួន៧,០០០នាក់ នៅជំរំសាកែវ (ក្រុមប្រជាជនដែលមិនស្រឡាញ់កុម្មុយនិស្ត) ឲ្យត្រឡប់ចូលទៅក្នុងដីខ្មែរវិញ ដើម្បី«ច្បាំងយួន» គឺឲ្យទៅរកសេចក្តីស្លាប់យ៉ាងពិតប្រាកដ... បើមិនស្លាប់ដោយប៉ុល-ពត ក៏ស្លាប់ដោយពួកចោរនិងពួកប៉ារ៉ា...។

បើខ្មែរណាចង់ឆ្លងទៅប្រទេសទី៣ ត្រូវពួកសឺន-សានចោទថា «មិនស្នេហាជាតិ» ។ ផ្ទុយទៅវិញ សឺន-សានបានអន្តរាគមន៍ជួយតែពួកជនជាតិយួន ឲ្យបានទៅកាន់ប្រទេសទី៣ ។ លោក Shawcross បានសរសេរថា ៖ «នៅក្នុងចំណោមប្រជាជនឥណ្ឌូចិន ជនជាតិខ្មែរជាប្រជាជនដែលមានភ័ព្វសំណាងដ៏តិចតួចបំផុត ។ សហរដ្ឋអាមេរិកបានទទួលយកប្រជាជនខ្មែរតែ៧៨,០០០នាក់តែប៉ុណ្ណោះ តទល់និងប្រជាជនយួន៥២០,០០០នាក់ និងប្រជាជនលាវ១០០,០០០នាក់ ហើយទាំងនេះ ទោះជាមានទារុណកម្មឃោរឃៅនៃរបបប៉ុល-ពត និងនយោបាយវ៉ាស៊ីនតោន ដែលប្រឆាំងនឹងរបបហេង-សំរិនយ៉ាងណាក៏ដោយ» (The Quality of Mercy - p.405) ។

❑

❑ ❑

## កាំបិតចិតដងឯង

★★★ នៅចុងបំផុតទៅ ការបង្កើតជំរំខ្មែរសេរីនៅព្រំប្រទល់ របស់សហការអាមេរិកាំង-សឺនសាន ក៏មានលំនាំដូចជាការបង្កើតសាធារណរដ្ឋភ្នំពេញ កាលក្នុងព្រឹត្តិការណ៍ «១៨មីនា» ដូច្នោះដែរ... គឺជាការបង្កើតទីកន្លែងមួយ សំរាប់ទាក់ទាញយួន ឲ្យមានលេសចូលមកសម្លាប់ជនជាតិខ្មែរយ៉ាងងាយស្រួល ។ កាលណាយួនវាយប្រហារចូលមកក្នុងជំរំខ្មែរ គឺវាតម្រង់មករកជំរំសឺន-សានមុនគេ ចំណែកជំរំរបស់ពួកខ្មែរក្រហម ពួកវាឥតរវីរវល់ទេ ។ អ្នកផងមានសេចក្តីងឿងឆ្ងល់ណាស់ថាកាលណាមានការផ្តល់គ្រឿងអាវុធភស្តុភារសៀ្បងយ៉ាងច្រើនទៅដល់ជំរំសឺន-សាន គឺតែងតែមានរទេះតង់យួនចូលមកដល់មួយរំពេជ ហាក់ដូចជាវាដឹងក្លិនជាមុន ។ នៅពេលនោះ សៀមក៏បាញ់កាំភ្លើងធំទៅលើកងទ័ពយួន ជាការបណ្តាលឲ្យប្រជាជនភៀសខ្លួនស្លាប់រាប់រយនាក់រាល់ពេល នៅកណ្តាលភ្លើងសង្គ្រាមសៀម-យួន ដោយមិនដឹងថាទទួលរងគ្រោះស្លាប់ដោយគ្រាប់ខាងណា ។

★★★ នៅត្រង់ចំណុចនេះ លោក Shawcross បានសរសេរថា ៖ «នៅ៤ខែដំបូងនៃឆ្នាំ១៩៨៣, ក្នុងរដូវរាំងស្ងួត, ពួកយួនបានចូលមកវាយប្រហារជំរំជាច្រើនកន្លែងនៅព្រំប្រទល់ ។ ខ្មែររាប់រយនាក់ត្រូវស្លាប់ រាប់ពាន់នាក់ត្រូវរបួស ហើយចំនួន៩០,០០០នាក់ (ក្នុងចំណោមខ្មែរភៀសខ្លួន ២០០,០០០នាក់) ត្រូវបាត់បង់ទីជំរក

ព្រមទាំងត្រូវបង្ខំខ្លួន ជាមួយនិងពួកកូនក្មេង រើបង្ហិចទៅទីកន្លែងផ្សេងៗជាច្រើនលើកច្រើនសា ។ គ្មានកន្លែងណានៅព្រំប្រទល់ ដែលមានសេចក្តីសុខនោះទេ ពួកយួន (ក៏ដូចតែពួកខ្មែរក្រហម) ច្រើនតែបាញ់ទៅលើប្រជាជនស៊ីវិល ហើយមានពេលខ្លះ ពួកយួនចាប់ជនភៀសខ្លួនញាត់ក្នុងរូងដី (Bunker) ហើយគ្រវែងគ្រាប់បែកចូលទៅក្នុងនោះ» (The Quality of Mercy- p.407) ។

★★★លក្ខណៈមួយទៀត ដូចជាសាធារណរដ្ឋភ្នំពេញ គឺកម្លាំងទីពីររបស់សឺន-សាន បានបង្កើតចោរកម្ម, ឃាតកម្មបិទមុខ, ការជំរិតប្រជាជន, ការលួចប្រពន្ធគេ, ការដាក់គ្រាប់បែកបំផ្ទុះជំរំសេរីគ្នាឯង (ទង្វើជិះជាន់របស់ វណ្ណា-សារេន នៅម៉ាក់មូនដែលមានខ្មែរ៨០០,០០០នាក់, អ៊ិន-សាខន នៅណងសាមេត, ចោរកម្មរបស់ André Ouk Thol ហៅសូរិយ៉ាវង្ស, ការជំរិតរបស់ ធូ-ថុន រ.ជ.រ.ប.ខ)...បានធ្វើឲ្យពួកទ័ពសេរីក្លាយទៅជាទ័ពចោរព្រៃ មិនមែនជាទ័ពប្រយុទ្ធដូចពួកខ្មែរក្រហម ។ ទាំងនេះបានធ្វើឲ្យកិត្យានុភាពនៃកងទ័ពសេរីរបស់សឺន-សាន ហើយនិងសក់-ស៊ុតសាខន ធ្លាក់ដល់បាតដាល ។

★★★ សឺន-សានហើយនិងសក់-ស៊ុតសាខន មិនបានព្រាងទុកជាមុនថា កងទ័ពវៀតណាមត្រូវដកចេញពីប្រទេសកម្ពុជានោះទេ ។ ម្ល៉ោះហើយ ពេលសម័យកាលនៃការបោះឆ្នោតមកដល់ អ្នកទាំងពីរក៏ត្រូវដាច់ទុង ។ ដោយពួកគេបានបំផ្លាញកងទ័ពសេរីខ្លួនឯងខ្ទេចខ្ទីអស់ទៅហើយ (ដូចតែពួកគេបានបំផ្លាញសាធារណរដ្ឋលន់-នល់)... សឺនសាន-សក់ស៊ុតសាខន ក៏បានបាត់បង់មធ្យោបាយ, ខ្វះប្រជារាស្ត្រគាំទ្រនិងកម្លាំងកងទ័ព ដើម្បីទប់ទល់នឹងសេចក្តីស្វាហាប់របស់ហ៊ុន-សែន ។ ពួកកម្លាំងទីពីរក៏ត្រូវបំបែកជួរម្តងទៀត... ម្ខាងលូនទៅបំរើស្តេច ម្ខាងលូនទៅបំរើបក្សប្រជាជន ។៚

❑ ❑

❑